**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាសកម្មភាពជនពិការ**

លេខ : ០០៣ កសជ.សសរ

# សេចក្តីសម្រេច
# ស្តីពី
# រូបសញ្ញា ត្រារបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ និងត្រារបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញអនុក្រឹត្យលេខ ៥៤/អនក្រ.បក/ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ២១៦/អនក្រ.បក/ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ
- យោងលិខិតលេខ ០៦៨ ស.ជ.ណ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៤ របស់ក្រសួងមហាផ្ទៃ ស្តីពីខ្ទាតត្រាសម្រាប់គណៈរដ្ឋមន្ត្រី ក្រសួង ស្ថាប័នចំណុះគណៈរដ្ឋមន្ត្រី និងអង្គភាពនានា
- ការចាំបាច់របស់ក្រុមប្រឹក្សាសកម្មភាពជនពិការ។

## សម្រេច

**ប្រការ ១ ._**

ត្រូវបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវរូបសញ្ញារបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ ដែលមានអត្ថន័យដូចខាងក្រោម៖

រូបសញ្ញា គឺមានរាងជារង្វង់ ដោយផ្នែកខាងក្រៅរំលេចដោយរូបស្លឹកឈើ ឡោមព័ទ្ធ១/៣ខាងក្រោម នៃរង្វង់ព័ណ៌បៃតងតំណាងឲ្យបរិស្ថានស្រស់បំព្រង និងវិស័យកសិកម្ម ដែលជាវិស័យអាទិភាពរបស់ព្រះរាជាណាចក្រកម្ពុជា។

ផ្នែកខាងលើក្នុងរង្វង់នៃស្លឹកឈើ មានសរសេរអក្សរជាខេមរៈភាសារាងកោងចុះក្រោមថា " ក្រុមប្រឹក្សាសកម្មភាពជនពិការ " ដែលជាយន្តការសម្របសម្រួលនិងពិគ្រោះយោបល់ថ្នាក់ជាតិលើវិស័យពិការភាពនៅកម្ពុជា។ ផ្នែកខាងក្រោមក្នុងរង្វង់នៃស្លឹកឈើ មានសរសេរអក្សរជាភាសាអង់គ្លេសរាងកោងឡើងលើថា " DISABILITY ACTION COUNCIL" ជាតំណាងបញ្ជាក់ពីការទំនាក់ទំនងថ្នាក់អន្តរជាតិ និងសមាជិកភាពរបស់កម្ពុជា ក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ។ អក្សរទាំងពីរភាសានេះគឺមានព័ណ៌ផ្ទៃមេឃខ្ចី។

ចំកណ្តាលផ្នែកខាងលើ មាននិមិត្តសញ្ញាជនពិការអង្គុយលើរទេះ តំណាងឲ្យវិស័យពិការភាពនិងជនពិការ។ ចំកណ្តាលផ្នែកខាងក្រោមមាននិមិត្តសញ្ញាចាប់ដៃ តំណាងឲ្យកិច្ចសហប្រតិបត្តិការទាំងថ្នាក់ជាតិនិងថ្នាក់អន្តរជាតិ។ និមិត្តសញ្ញាទាំងពីរខាងលើនេះគឺមានព័ណ៌ផ្ទៃមេឃខ្ចី។

**ប្រការ ២ ._**

ត្រូវបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវត្រារបស់ **ក.ស.ជ.** និងត្រារបស់អគ្គលេខាធិការដ្ឋាន **ក.ស.ជ.** ដែលមានខ្លឹមសារដូចខាងក្រោម៖

ត្រាទឹករបស់ក្រុមប្រឹក្សាសកម្មភាពជនពិការមានទំហំ៤៣ម.ម មានរាងជារង្វង់។ ផ្ទៃខាងក្នុងរង្វង់ផ្នែកខាងលើមានសរសេរអក្សរថា **ព្រះរាជាណាចក្រកម្ពុជា** និងផ្នែកខាងក្រោមមានអក្សរថា **ក្រុមប្រឹក្សាសកម្មភាពជនពិការ** ខណ្ឌដោយរូបផ្កាចន្ទន៍។ ចំកណ្តាលក្នុងរង្វង់ មានរំលេចដោយរូបប្រាសាទអង្គរវត្តកំពូលបី និងមាននិមិត្តសញ្ញាជនពិការជិះរទេះនៅខាងក្រោមរូបប្រាសាទ។

ត្រាទឹករបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការមានទំហំ៤១ម.ម មានរាងជារង្វង់។ ផ្ទៃខាងក្នុងរង្វង់ផ្នែកខាងលើ មានសរសេរអក្សរថា **ព្រះរាជាណាចក្រកម្ពុជា** និងផ្នែកខាងក្រោមមានអក្សរថា **អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ** ខណ្ឌដោយរូបផ្កាចន្ទន៍។ ចំកណ្តាលក្នុងរង្វង់ មានរំលេចដោយរូបប្រាសាទអង្គរវត្តកំពូលបី និងមាននិមិត្តសញ្ញាជនពិការជិះរទេះនៅខាងក្រោមរូបប្រាសាទ។

**ប្រការ ៣ ._**

គ្រប់សមាជិកក្រុមប្រឹក្សាសកម្មភាពជនពិការ គ្រប់អង្គភាពក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។/.

*រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៣*

**ជ.ក្រុមប្រឹក្សាសកម្មភាពជនពិការ**

**ប្រធាន**

**អ៊ិត សំហេង**

***ចម្លងជូន៖***

- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ: ០០៣ អកសជ.សណ

រូបសញ្ញាក្រុមប្រឹក្សាសកម្មភាពជនពិការ

ត្រាទឹកក្រុមប្រឹក្សាសកម្មភាពជនពិការ

ត្រាទឹកអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ